# សច្ចិកិរិយាកិច្ច

(កិច្ចធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន)

សៀវភៅនេះ ចែកជាធម្មទាន

ព. ស. ២៥៥០ គ. ស. ២០០៦

សូមនមស្សការ ចំពោះព្រះរតនត្រ័យដែលជា
ទីពឹង ទីរលឹករបស់ខ្ញុំនិងពុទ្ធបរិស័ទទាំងឡាយ ។

សូមព្រះពុទ្ធសាសនា ឋិតនៅអស់កាល ៥០០០ វស្សា ។

# ពាក្យឧទ្ទិស

១, សូមឧទ្ទិសមគ្គផល ចំពោះ មាតា បិតា ដែលបាន បង្កើតរូបខ្ញុំ ។

២, សូមឧទ្ទិសមគ្គផល ចំពោះ សប្បុរសទាំងឡាយ ដែលបានផ្តល់ចំណែកបរិយត្តសទ្ធម្មដល់ខ្ញុំ ព្រមទាំង បង្ហាញផ្លូវប្រតិបត្តិធម៌ ដល់ខ្ញុំ ។

៣, សូមថ្លែងអំណរគុណ ចំពោះ អ្នកគ្រប់គ្រងប្រទេស ដែលបានផ្តល់ សុខសន្តិភាពដល់ប្រជាជន មានទាំង រូបខ្ញុំផងដែរ ។

៤, សូមថ្លែងអំណរគុណ ដល់បងប្អូន ញាតិមិត្ត ដែល បានធ្វើសេចក្តីល្អ ដល់ខ្ញុំ ។

៥, សូមសព្វសត្វទាំងពួងបានចំរើនក្នុងព្រះពុទ្ធសាសនា ។

កម្ពុជា, ភ្នំពេញ ឆ្នាំ ២០០៦

**ហៅ អាចារ្យ ថាន**

# សេចក្តីផ្តើម

កិច្ចប្រតិបត្តិក្នុងអរិយសច្ច មានៈ

ក. បរិញ្ញាកិច្ច គឺកិច្ចកំណត់ដឹងនូវបញ្ចុបាទានក្ខន្ធទុក្ខ

ខ. បហានកិច្ច គឺកិច្ចលះបង់នូវតណ្ហា

គ. សច្ឆិកិរិយាកិច្ច គឺកិច្ចធ្វើឱ្យជាក់ច្បាស់នូវ ព្រះនិព្វាន

(សេចក្តីស្ងប់ដ៏កំពូល)

ឃ.ភាវេតព្វកិច្ច គឺកិច្ចចំរើនអដ្ឋង្គិកមគ្គ

កិច្ចទាំង ៤ យ៉ាងនេះ គប្បីប្រកប ៤ លើកៈ

ក្នុងលើកទី ១ កើតបាន សោតបត្តិមគ្គចិត្ត

ក្នុងលើកទី ២ កើតបាន សកទាមិមគ្គចិត្ត

ក្នុងលើកទី ៣ កើតបាន អនាគាមិមគ្គចិត្ត

ក្នុងលើកទី ៤ កើតបាន អរហត្តមគ្គចិត្ត

សរុបកិច្ចទាំងអស់ រាប់បាន ១៦ (៤ x ៤= ១៦) ហៅថា

សោឡសកិច្ច ។

ក្នុងបណ្ដាកិច្ចទាំង ១៦ សូមលើកយកសច្ឆិកិរិយាកិច្ច គឺកិច្ចធ្វើឱ្យជាក់ច្បាស់នូវ សេចក្ដីស្ងប់ដ៏កំពូលមកសំដែង ដោយយោងទៅលើពុទ្ធវចនៈដកស្រង់ពីក្នុងសីតិភាវៈសូត្រ ។ កិច្ចនេះ លំបាកនឹងសំដែងប្រាប់ដោយលោកវោហារជាពន់ពេកណាស់ ព្រោះធមិដែលគប្បីធ្វើឱ្យជាក់ច្បាស់នោះ ជាធមិដែលគប្បីដឹងចំពោះខ្លួន ។ សេចក្ដីអធិប្បាយក្នុងខាងមុខ បានត្រឹមតែប្រាប់នូវធមិ ជា គ្រឿងប្រកបសំរាប់បំពេញសមត្ថភាពឱ្យបានជាបេក្ខភាពប៉ុណ្ណោះ ពុំបានប្រាប់អំពីវិធីធ្វើយ៉ាងដូចម្ដេចនោះឡើយ ។ សូមសប្បុរសទាំងឡាយ មេត្តាជួយ តម្រង់ផ្លូវតាមការគួរ ។

សេចក្ដីផ្ដើម ចប់

# ដើម្បីធ្វើឱ្យជាក់ច្បាស់ នូវសេចក្ដីស្ងប់ដ៏កំពូល

វដ្តសង្សារ* វែងឆ្ងាយណាស់ ។ ជីវិតសត្វលោកក្នុងជាតិនីមួយៗ ប្រព្រឹត្តទៅក្នុងចំរៀកកាលដ៏ខ្លីបំផុត នៃវដ្តសង្សារប៉ុណ្ណោះ ។ បើក្នុងជាតិនេះ មានសេចក្ដីសុខច្រើន ក៏គប្បីរំពឹងឃើញនូវសេចក្ដីទុក្ខកើតឡើងក្នុងកាលខាងក្រោយ ត្បិតអីសុខនិងទុក្ខជាគូផ្លាស់ប្ដូរវេនគ្នា ៖

"**សុខស្សានន្តរំទុក្ខំ**" ទុក្ខកើតក្នុងលំដាប់នៃសុខ

"**ទុក្ខស្សានន្តរំសុខំ**" សុខកើតក្នុងលំដាប់នៃទុក្ខ ។

លុះឃើញច្បាស់ដូច្នេះ ទើបចុះចិត្តស្វែងរកសុខម្យ៉ាងដែលមិនមានទុក្ខមកផ្លាស់ប្ដូរ ។ សុខម្យ៉ាងនោះគឺ **សេចក្ដីស្ងប់** ។ សេចក្ដីស្ងប់កើតមាន ព្រោះមានចិត្តរួចផុត ចិត្តដែលរួចផុត ព្រោះប្រាសចាកតម្រេក ដែលប្រាសចាកតម្រេក ក៏ព្រោះតែចិត្តនោះមានសេចក្ដីនឿយណាយ ។ បុគ្គលមានចិត្តនឿយណាយជាក់ច្បាស់ក្នុងវដ្តសង្សារ បណ្ឌិតឱ្យឈ្មោះថាជា "**ភិក្ខុ**" ។

---

*វដ្តសង្សារ ក្នុងទីនេះ សំដៅយក ដំណើរអន្ទោលទៅមកក្នុងភពដ៏ច្រើនអនេករបស់សត្វលោក មិនប្រកបយកន័យដ៏ទៃឡើយ ។

មានព្រះសូត្រថា (សីតិភាវៈសូត្រ) :

"ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ ជាអ្នកគួរដើម្បីធ្វើឱ្យជាក់ច្បាស់នូវសីតិភាវៈ (ភាពជាអ្នកស្ងប់) ដ៏កំពូល, ធម៌ ៦ តើដូចម្ដេច? ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ :

១- រមែងគ្រប់សង្កត់ចិត្ត ក្នុងសម័យដែលគួរគ្រប់សង្កត់.

២- រមែងផ្គងចិត្ត ក្នុងសម័យដែលគួរផ្គង.

៣- រមែងរីករាយចិត្ត ក្នុងសម័យដែលគួររីករាយ.

៤- រមែងដាក់ចិត្តព្រងើយៗ ក្នុងសម័យដែលគួរដាក់ចិត្តព្រងើយៗ.

៥- រមែងបង្អោនចិត្ត ទៅក្នុងធម៌ដែលប្រណិត.

៦- រមែងជាអ្នកត្រេកអរក្រៃលែងក្នុងព្រះនិព្វាន.

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ នេះឯង ជាអ្នកគួរដើម្បីធ្វើឱ្យជាក់ច្បាស់ នូវសីតិភាវៈដ៏កំពូល (សេចក្ដីស្ងប់ដ៏កំពូល)" ។

**ក្នុងចំណុចធម៌ទី ១** : សម័យដែលគួរគ្រប់សង្កត់ចិត្ត បានដល់ : ①

② - សម័យចិត្តប្រកបដោយកាមឆន្ទៈ (១)

- សម័យចិត្តប្រកបដោយព្យាបាទ

- សម័យចិត្តរួញរា ព្រោះងោកងុយ និងខ្ជិលច្រអូស (ថីនមិទ្ធ)

**ក្នុងចំណុចធម៌ទី ២** : សម័យដែលគួរផ្គងចិត្ត បានដល់ :

- សម័យចិត្តរាយមាយ ឆ្អឹះកកាយរឿងរ៉ាវពីក្នុងអតីតកាល (ឧទ្ធច្ចៈ កុក្កុច្ចៈ)

**ក្នុងចំណុចធម៌ទី ៣** : សម័យដែលគួររីករាយចិត្ត បានដល់ :

- សម័យដែលបានគ្របសង្កត់ចិត្តរួចហើយ
- សម័យដែលបានផ្គងចិត្តទុករួចហើយ
- សម័យដែលចិត្តកើតសេចក្តីអផ្សុក

**ក្នុងចំណុចធម៌ទី ៤** :សម័យដែលគួរដាក់ចិត្តព្រងើយៗបានដល់ :

- សម័យចិត្ត រវល់ខ្វល់ខ្វាយក្នុងការងារដែលតាក់តែងឡើង ដោយចិត្តដ៏មិនមែនជាឧបាយ នៃបញ្ញា (២)

---

(១) កាមឆន្ទៈ គឺសេចក្តីស្ទើរចិត្តប្រព្រឹត្តក្នុងកាម មានកម្លាំងរុញឱ្យកាយវាចាធ្វើតាមបំណង រីឯកាមតណ្ហា គឺសេចក្តីប្រាថ្នាក្នុងកាមយ៉ាងអន្ទះអន្ទែង ងំនៅតែក្នុងចិត្តតែប៉ុណ្ណោះ ។ (២) បញ្ញា ជាសោភណចេតសិក ការធ្វើអំពើអាក្រក់ មិនឱ្យឈ្មោះថា មានបញ្ញាទេ គឺគ្មានបញ្ញា ដូច្នេះមិនគួរប្រើពាក្យថា សុបញ្ញា ឬទុបញ្ញា ក្នុងធម្មគាធិប្បាយឡើយ ។

ក៏ឯបញ្ញាដឹងសម័យចិត្ត ដែលប្រកបដោយកាមឆន្ទៈជាដើម[១] នោះ គឺដឹងបានអាស្រ័យដោយមានសតិសម្បជញ្ញៈ កើតឡើងក្នុងខាងក្រោយ ប៉ុន្តែបើសតិនោះកើតក្នុងខាងដើមទី ក៏មិនមានកិច្ចអ្វីគប្បីគ្របសង្កត់ចិត្តទេ ត្បិតអីនីវរណៈធម៌មិនបានឱកាសចូលដល់ក្នុងចិត្តឡើយ ។ កាលដែលសតិកើតឡើងក្នុងខាងក្រោយដូច្នោះ ក៏គួរជ្រាបសេចក្តីថា ចិត្តនោះៗបានធ្លាក់ចុះទៅក្នុងអំណាច នៃនីវរណៈធម៌អស់មួយគ្រាទៅហើយ ។ ហេតុការណ៍បែបនេះ រមែងមានប្រាកដដល់អ្នកកំពុងប្រកប ។ កាលណាអ្នកប្រកបព្យាយាមប្រកបរឿយៗ គេនឹងបានដឹងសារៈសំខាន់របស់សតិ ហើយខិតខំចំរើនសតិបដ្ឋានដោយរឿយៗ ។

**ក្នុងចំណុចធម៌ទី ៥:** រមែងបង្អោនចិត្តទៅក្នុងធម៌ដែលប្រណិត ។ គឺសព្វសង្ខារសមថោ ១ សព្វូបធិប្បដិនិស្សគ្គោ ១ តណ្ហក្ខយោ ១ វិរាគោ ១ និរោធោ ១ ។

---

(១) ពាក្យ "កាមឆន្ទៈជាដើម" គឺប្រាថ្នាយោងទៅដល់ប្រកបដោយព្យាបាទ ថីនមិទ្ធ អផ្សុក ឧទ្ធច្ចៈ កុកច្ចៈ និងរវល់ខ្វល់ខ្វាយ ។

-សព្វសង្ខារសមថោ គឺធមិជាគ្រឿងរំងាប់សង្ខារទាំងពួង (១)

-សព្វូបធិប្បដិនិស្សគ្គោ គឺធមិជាគ្រឿងលះកិលេសទាំងពួង (២)

-តណ្ហក្ខយោ គឺធមិជាគ្រឿងអស់ទៅនៃតណ្ហា (៣)

-វិរាគោ គឺធមិជាគ្រឿងប្រាសចាកតម្រេក (៤)

-និរោធោ គឺធមិជាគ្រឿងរលត់ស្និទ្ធ (៥)

---

(១) សង្ខារទាំងពួង គឺសង្ខារលោក និងសង្ខារធមិ ។ សង្ខារលោក គឺ ឧបាទិន្នកសង្ខារដែលមានវិញ្ញាណគ្រប់គ្រង និងអនុបាទិន្នកសង្ខារ ដែលគ្មានវិញ្ញាណគ្រប់គ្រង ។ សង្ខារធមិ គឺ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អនេញ្ជាភិសង្ខារ កាយសង្ខារ (ដង្ហើមចេញចូល) វចីសង្ខារ (ចិត្ត) និងចិត្តសង្ខារ (វេទនា និងសញ្ញា) ។

(២) កិលេសទាំងពួង ពោលដោយសង្ខេប គឺ អវិជ្ជា តណ្ហា ឧបាទាន។ ពោលដោយកណ្តាលមាន ១០ គឺ លោភ ទោស មោហ មានៈ ទិដ្ឋិ វិចិកច្ឆា ថីនមិទ្ធ ឧទ្ធច្ច អហិរិក អនោត្តប។ ពោលដោយអស់ជើងមាន ១៥០០ គឺ កិលេស ១០ x (នាមធមិ ៧៥ + រូបធមិ ៧៥ )។ នាមធមិ ៧៥ គឺចិត្ត ១ ចេតសិក ៥២ និប្ផន្នរូប ១៨ ជាតិ ១ ជរា ១ ព្យាធិ ១ មរណៈ ១ ។ រូបធមិ គឺជាដៃគូនិងគ្នា ។

(៣) តណ្ហា មាន៣ គឺកាមតណ្ហា សេចក្តីប្រាថ្នាក្នុងកាម, ភវតណ្ហា សេចក្តីប្រាថ្នាក្នុងកំណើត វិភវតណ្ហា សេចក្តីប្រាថ្នាក្នុងការបាត់កំណើត។

(៤) តម្រេក គឺ រាគៈ, មាន ៣ គឺ កាមរាគៈ រូបរាគៈ និងអរូបរាគៈ ។

(៥) គ្រឿងរលត់ស្និទ្ធ សំដៅយកនិរោធសមាបត្តិ ដែលមានតែព្រះអរហន្តថ្នាក់ខ្ពស់ៗ ទើបសំរេចបាន មានព្រះសព្វញ្ញុពុទ្ធ ព្រះបច្ចេកពុទ្ធជាដើម ។ ប៉ុន្តែចំពោះសាវ័កដ៏មានអាយុ គឺសេចក្តីស្ងប់ដ៏កំពូលនេះឯង ។

**ក្នុងចំណុចធម៌ទី ៦** : រមែងជាអ្នកត្រេកអរ ក្រៃលែងក្នុងព្រះនិព្វាន ។ និព្វានគឺសេចក្ដីស្ងប់ដ៏កំពូល ដែលក្នុងនោះ មិនមានវដ្ដ មិនមានកង្វល់ មិនមានបច្ច័យប្រជុំតាក់តែង និងមិនចេះប្រែប្រួល ។ ដែលថាមិនមានវដ្ដ គឺមិនមានដំណើរវិលវង់ នៃកិលេស កម្ម និងវិបាក។ ដែលថាមិនមានកង្វល់ គឺ សំដៅដល់ន័យថា ចិត្តក៏ស្រឡះផេង ។ ដែលថាមិនមាន បច្ច័យប្រជុំតាក់តែង បានសេចក្ដីថា ល្គឹកណាតែបានកើតឡើងហើយ អារម្មណ៍ព្រះនិព្វាននោះ ក៏តាំងនៅឯកឯងមិនអាស្រ័យអ្វីសោះ ដរាបដល់ចិត្តធ្លាក់ចុះកាន់ភវង្គទើបអស់ លុះកើតឡើងក្នុងលើកក្រោយៗទៀត ក៏កើតជាស្វ័យប្រវត្តិ មិនបាច់ចាំនឹករកដោយសតិឡើយ បើទោះបីជាខំនឹករកក៏មិនឃើញដែរ ។ ដែលថាមិនចេះប្រែប្រួល គឺអារម្មណ៍ព្រះនិព្វាននោះ នៅតែដដែល ធ្លាប់ឃើញក្នុងគ្រាមុនយ៉ាងដូចម្ដេច ក្នុងគ្រាក្រោយៗក៏ដូច្នោះ មិនឃ្លាតពីសភាវដែលហៅថា ស្ងប់គ្មានគូ នោះឡើយ ។ សេចក្ដីដូចពិពណ៌នារួចហើយបញ្ជាក់បានច្បាស់ថា ព្រះនិព្វាន គឺព្រះនិព្វានតែម្យ៉ាងប៉ុណ្ណោះ ។ រីឯសឧបាទិសេសនិព្វាន ក៏នៅតែជាព្រះនិព្វាន ប្លែកគ្នានៅត្រង់អារម្មណ៍តាំងនៅបានត្រឹមតែក្នុងរយៈពេលខ្លី ចិត្តក៏ធ្លាក់ចុះកាន់ភវង្គ ម្យ៉ាងទៀត

យូរៗទើបកើតជាស្វ័យប្រវត្តិបានម្តង ប្រការនេះព្រោះហេតុអ្វី ? ព្រោះនៅមាន "**ឧបាធិ**"(១) ដែលជាឧបាទានសល់នៅមិនទាន់បានលះ, ដូចជា **សោតាបត្តិមគ្គ** **សកទាគាមិមគ្គ** លះបានតែ **ទិដ្ឋុបាទាន** និង **សីលព្វតុបាទាន** **អនាគាមិមគ្គ** លះបាន **កាមុបាទាន** ១ ថែមទៀត នៅសល់ **អត្តវាទុបាទាន** មិនទាន់បានលះដោយអស់ជើង ។ ចំណែកឯអនុបាទិសេសនិព្វាន គឺជា និព្វានសម្រេចដោយព្រះអរហន្ត ដែលលោកលះឧបាទានអស់រលីង គ្មានសេសសល់ ហើយខន្ធ ៥ ដែលកំពុងប្រព្រឹត្តទៅគឺជាខន្ធដែលមិនជាប់ទាក់ទិនដោយឧបាទាន សេចក្តីនេះ ទើបអនុបាទិសេសនិព្វាន ដែលព្រះសព្វញ្ញុពុទ្ធទ្រង់ប្រកាសហើយ រមែងបានប្រយោជន៍ប្រាកដដល់ ជីវិតរស់នៅរបស់សត្វលោក ។

ដើម្បីធ្វើឱ្យជាក់ច្បាស់
នូវសេចក្តីស្ងប់ដ៏កំពូល ចប់.

---

(១) ឧបាធិ សព្ទ ប្រែថា កាកើតឡើងនៃខន្ធ ៥ នេះយោងតាមអត្ថន័យ យោងតាមអត្ថរស គឺជាឧបាទាន ពីព្រោះខន្ធ ៥ រមែងជាប់មកជាមួយនូវឧបាទាន់ ។ សូមពិនិត្យពុទ្ធវចនៈត្រង់ "សព្វលោកេអនភិរតសញ្ញា" ។

# ដើម្បីប្រកបដោយធម៌ ៦

ដែលគួរដើម្បីធ្វើឱ្យជាក់ច្បាស់ នូវសេចក្តីស្ងប់ដ៏កំពូល គប្បីប្រកបដោយធម៌ ៦ ដូចបានពោលហើយ ។ ដែលគួរដើម្បីប្រកបដោយធម៌ ៦ គប្បីអប់រំចិត្ត ។ ក្នុងការអប់រំចិត្ត បែបខ្លះគឺសង្រួម បែបខ្លះគឺចំរើនសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ឯបែបខ្លះទៀតគឺតាមឯកទេសផុសចេញអំពីសជាតិបញ្ញា[១] ។ ព្រះសម្មាសម្ពុទ្ធ ជាបរមគ្រូទ្រង់ទូន្មានសាវ័កដូចតទៅនេះ :

" ទូរង្គមំ ឯកចរំ វិចិត្តនោះត្រាច់ចរតែឯងទៅកាន់ទីឆ្ងាយ

អសរីរំ គូហា សយំ ជាធម្មជាតិឥតរូប មានកាយជាទីអាស្រ័យ

យេ ចិត្តំ សញ្ញមេស្សន្តិ អ្នកទាំងឡាយសង្រួមចិត្តនោះបានហើយ

មោក្ខន្តិ មារ ពន្ធនា " នឹងបានរួចផុតពីចំណងនៃមារ ។

(១) សជាតិបញ្ញា គឺ បញ្ញាដែលមានជាប់ពីកំណើតមកស្រាប់ៗ ។

" ....... .

ចិត្តស្ស ធមថោ សាធុ សេចក្តីទូន្មានចិត្តជាការប្រសើរ

ចិត្តំ ទន្តំ សុខាវហំ " ចិត្តដែលអប់រំល្អហើយរមែងនាំសុខមកឱ្យ ។

" ........

ឧជុំ ករោតិ មេធាវី " អ្នកមានប្រាជ្ញាទាំងឡាយរមែងពត់ចិត្ត

ឱ្យត្រង់ ។

"អនវដ្ឋិត ចិត្តស្ស បុគ្គលអ្នកមានចិត្តរវើរវាយមិនគង់វង់

សទ្ធម្មំ អវិជានតោ មិនដឹងច្បាស់នូវព្រះធម៌ គឺហេតុនៃ

សេចក្តីស្ងប់

បរិប្លវ បសាទស្ស មានសេចក្តីជ្រះថ្លារសាត់អណ្តែតទៅ

បញ្ញា ន បរិបូរតិ បញ្ញាមិនចំរើនដល់បុគ្គលនោះឡើយ ។

អនវស្សុត ចិត្តស្ស វីបុគ្គលអ្នកមានចិត្តហឺ មិនជំពាក់ដោយ

ត្រេកអរ

អនន្វា ហត ចេតសា មិនប្រទូស្តរ៉ាយជាមួយអារម្មណ៍

ដោយទោសៈ

បុញ្ញ បាប បហីនស្ស ជាអ្នកលះបុណ្យ និងបាបបានអស់ហើយ

នត្ថិ ជាគរតោ ភយំ" សេចក្ដីភ័យរមែងមិនមានដល់បុគ្គលអ្នកភ្ញាក់រលឹកយ៉ាងដូច្នោះ ។

នៅមានសេចក្ដីបញ្ជាក់បន្ថែមទៀតក្នុងធមិ ៦ ត្រង់បញ្ញាដឹងញ៉ាំងចិត្តឱ្យរីករាយក្នុងសម័យដែលគួររីករាយ និងបញ្ញាដឹងដាក់ចិត្តព្រងើយៗ ក្នុងសម័យដែលគួរដាក់ចិត្តព្រងើយៗ ។ បញ្ញានោះៗ គប្បីកើតបានអំពីចំរើនដោយល្អ នូវអនាបានស្សតិកម្មដ្ឋាន ដែលមាននៅក្នុងគិរិមានន្ទសូត្រត្រង់សញ្ញាទី ១០ គឺអានាបានស្សតិ សតិកំណត់ក្នុងដង្ហើមចេញចូលជាអារម្មណ៍ សូមស្វែងរកមើលក្នុងសូត្រនោះ ត្រង់ចំណុចសិក្សាអំពីចិត្ត ។ តទៅ សូមលើកយកគិរិមានន្ទសូត្រទាំងមូលមកចុះតែម្ដង ក្រែងលោកើតបានជាប្រយោជន៍ ដទៃ ដ៏ច្រើន ។

## <u>គិរិមានន្ទសុត្ត</u>

ឯវមេសុតំ ខ្ញុំម្ចាស់ឈ្មោះអានន្ទបានស្ដាប់មកហើយ យ៉ាងនេះ ។

ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ, ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ សម័យមួយព្រះដ៏មានព្រះភាគជាម្ចាស់, ស្ដេចគង់នៅវត្ត ជេតវនវិហារ, ជាអារាមរបស់អនាថបិណ្ឌិក សេដ្ឋីជិតក្រុងសាវត្ថី ។

តេន ខោ បន សមយេន, អាយស្មា គិរិមានន្ទោ អពាធិកោ ហោតិ ទុក្ខិតោ ពាឡ្ហគិលានោ ក្នុងសម័យនោះឯង, ព្រះគិរិមានន្ទដ៏មានអាយុ ជាអ្នកមានអាពាធ, ប្រកបដោយទុក្ខវេទនាជាជំងឺធ្ងន់ ។

អថ ខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ គ្រានោះឯងព្រះអានន្ទដ៏មានអាយុក៏ចូលទៅគាល់ ព្រះដ៏មានព្រះភាគជាម្ចាស់, ត្រង់ទីដែលព្រះអង្គគង់នៅ ។

ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ, ហើយគង់នៅក្នុងទីមួយដ៏សមគួរ ។

ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច លុះព្រះអានន្ទដ៏មានអាយុ គង់ក្នុងទីមួយដ៏សមគួរហើយ, ក៏បានក្រាបទូលនូវពាក្យនេះនឹងព្រះដ៏មានព្រះភាគថា ។

អយស្មាភន្តេ គិរិមានន្ទោ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ បពិត្រព្រះអង្គដ៏ចំរើន, ព្រះគិរិមានន្ទដ៏មានអាយុ មានអាពាធប្រកប ដោយទុក្ខវេទនា ជាជម្ងឺធ្ងន់ ។

សាធុ ភន្តេ ភគវា, យេនាយស្មា គិរិមានន្ទោ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន, ខ្ញុំព្រះអង្គ សូមឱកាស, រីគិរិមានន្ទ ដ៏មានអាយុស្ថិតនៅក្នុងទីណា, សូមព្រះអង្គទ្រង់ ព្រះមេត្តា ស្ដេចទៅក្នុងទីនោះ, ដើម្បីនឹងបានអនុគ្រោះដល់លោក ។

សចេ ខោ ត្វំ អានន្ទ គិរិមានន្ទស្ស ភិក្ខុនោ ឧបសង្កមិត្វា ទសសញ្ញា ភាសេយ្យាសិ ព្រះដ៏មានព្រះភាគជាម្ចាស់ ទើបត្រាស់ តបថា, ម្នាលអានន្ទ, បើដូច្នោះលោកគប្បីចូលទៅរក គិរិមានន្ទភិក្ខុ ហើយសំដែងនូវសញ្ញា ១០ ប្រការ ។

ឋានំ ខោ បនេតំ វិជ្ជតិ, យំ គិរិមានន្ទស្ស ភិក្ខុនោ ទស សញ្ញា សុត្វា, សោ អាពាធោ ឋានសោ បដិប្បស្សម្ភេយ្យ ក៏ហេតុដែល

នឹងអពាធ របស់គិរិមានន្ទភិក្ខុ ស្ងប់រំងាប់ទៅបាននោះ, ព្រោះបានស្តាប់នូវសញ្ញា ១០ ប្រការ ។

កតមា ទស សញ្ញា ១០ ប្រការនោះដូចម្តេច ។

សញ្ញា ១០ ប្រការនោះគឺ :

| | | |
|---|---|---|
| អនិច្ចសញ្ញា | សេចក្តីសំគាល់ថាមិនទៀង | ១ |
| អនត្តសញ្ញា | សេចក្តីសំគាល់ថាមិនមែនខ្លួន | ១ |
| អសុភសញ្ញា | សេចក្តីសំគាល់ថាមិនល្អ | ១ |
| អាទីនវសញ្ញា | សេចក្តីសំគាល់ថាជាទោស | ១ |
| បហានសញ្ញា | សេចក្តីសំគាល់ក្នុងការលះបង់ | ១ |
| វិរាគសញ្ញា | សេចក្តីសំគាល់ក្នុងធម៌ដែលប្រាសចាករាគ | ១ |
| និរោធសញ្ញា | សេចក្តីសំគាល់ក្នុងធម៌ជាទីរលត់ | ១ |

សព្វលោកេ អនភិរត សញ្ញា សេចក្តីសំគាល់ក្នុងការមិន
ត្រេកអរ ក្នុងលោកទាំងពួង ១

★ ភគមា ចានន្ទ អនិច្ចសញ្ញា ម្នាលអានន្ទ អនិច្ចសញ្ញា នោះ ដូចម្តេច ។

ឥធា នន្ទភិក្ខុ អរញ្ញ គតោ វា រុក្ខមូលគតោ វា សុញ្ញ គារគតោ វា ឥតិ បដិ សញ្ចិក្ខតិ, ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ, ទៅនៅក្នុងព្រៃក្តី, ទៅនៅក្បែរគល់ឈើក្តី, ទៅនៅក្នុងផ្ទះទទេក្តី, រមែងពិចារណាយ៉ាងនេះ ថា ។

| | |
|---|---|
| រូបំ អនិច្ចំ | រូបមិនទៀង |
| វេទនា អនិច្ចា | វេទនាមិនទៀង |
| សញ្ញា អនិច្ចា | សញ្ញាមិនទៀង |
| សង្ខារា អនិច្ចា | សង្ខារទាំងឡាយមិនទៀង |
| វិញ្ញាណំ អនិច្ចន្តិ | វិញ្ញាណមិនទៀង ។ |

ឥតិ ឥមេសុ បញ្ចសុ ឧបាទានក្ខន្ធេសុ អនិច្ចានុបស្សី វិហរតិ ភិក្ខុមានប្រក្រតីពិចារណាឃើញរឿយៗ, ដោយសភាពជារបស់មិនទៀងក្នុងឧបាទានក្ខន្ធទាំង ៥ នេះ យ៉ាងនេះ ។

អយំ ទុច្ចតានន្ទ អនិច្ចសញ្ញា ម្នាលអានន្ទ នេះឯងតថាគត ពោលថា អនិច្ចសញ្ញា ។

★ កតមា ចានន្ទ អនត្តសញ្ញា ម្នាលអានន្ទ អនត្តសញ្ញា នោះដូចម្តេច ។ ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញា គារគតោ វា ឥតិ បដិសញ្ចិក្ខតិ, ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ, ទៅនៅក្នុងព្រៃក្តី, ទៅនៅកែ្បរគល់ឈើក្តី, ទៅនៅក្នុងផ្ទះទទេក្តី, រមែងពិចារណាយ៉ាងនេះថា ។

| | |
|---|---|
| ចក្ខុំ អនត្តា | ចក្ខុគឺក្នុងភ្នែកមិនមែនខ្លួនប្រាណ |
| រូបា អនត្តា | រូបទាំងឡាយមិនមែនខ្លួនប្រាណ |
| សោតំ អនត្តា | សោតគឺក្នុងត្រចៀកមិនមែនខ្លួនប្រាណ |
| សទ្ទា អនត្តា | សំឡេងទាំងឡាយមិនមែនខ្លួនប្រាណ |
| ឃានំ អនត្តា | ឃានៈគឺក្នុងច្រមុះមិនមែនខ្លួនប្រាណ |
| គន្ធា អនត្តា | ក្លិនទាំងឡាយមិនមែនខ្លួនប្រាណ |
| ជីវ្ហា អនត្តា | ជីវ្ហាគឺក្នុងអណ្តាតមិនមែនខ្លួនប្រាណ |
| រសា អនត្តា | រសទាំងឡាយមិនមែនខ្លួនប្រាណ |
| កាយោ អនត្តា | កាយមិនមែនខ្លួនប្រាណ |

ផោដ្ឋព្វា អនត្តា ផោដ្ឋព្វៈ គឺអារម្មណ៍ដែលគប្បីពាល់ត្រូវ ដោយកាយទាំងឡាយមិនមែនខ្លួនប្រាណ

ធម្មា អនត្តាតិ ធម៌ទាំងឡាយគឺអារម្មណ៍ ដែលកើតឡើង ជាមួយ នឹងចិត្ត មិនមែនខ្លួនប្រាណ ។

ឥតិ ឥមេសុ ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ អនត្តានុបស្សី វិហរតិ ភិក្ខុមានប្រក្រតីពិចារណាឃើញរឿយៗ, ដោយសភាពជារបស់មិនមែនខ្លួនប្រាណ ក្នុងអាយតនៈខាងក្នុង ៦ និងខាងក្រៅ ៦ នេះ យ៉ាងនេះ ។

អយំ វុច្ចតា នន្ទ អនត្តសញ្ញា ម្នាលអានន្ទ នេះឯងតថាគតពោលថា អនត្តសញ្ញា ។

★កតមា ចានន្ទ អសុភសញ្ញា ម្នាលអានន្ទ អសុភសញ្ញានោះដូចម្តេច ។ ឥធានន្ទ ភិក្ខុ ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា, តច បរិយន្តំ បូរន្នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ រមែងពិចារណាកាយនេះឯង, ខាងលើអំពីបាតជើងឡើងទៅ ខាងក្រោមអំពីចុងសក់ចុះមក, មានស្បែករុំព័ទ្ធដោយជុំវិញ ពេញទៅដោយរបស់មិនស្អាត មានប្រការផ្សេងៗ ។

អត្ថិ ឥមស្មិំ កាយេ មាននៅក្នុងកាយនេះ :

កេសា គឺសក់ទាំងឡាយ, លោមា រោមទាំងឡាយ, នខា ក្រចកទាំងឡាយ, ទន្តា ធ្មេញទាំងឡាយ, តចោ ស្បែក ។ មំសំ សាច់ ន្ហារូ សសៃទាំងឡាយ, អដ្ឋិ ឆ្អឹងទាំងឡាយ, អដ្ឋិមិញ្ជំ ខួរក្នុងឆ្អឹង វក្កំ ទាច ។ ហទយំ បេះដូង, យកនំ ថ្លើម, កិលោមកំ វាវ, បិហកំ ក្រពះ, បប្ផាសំ សួត ។ អន្តំ ពោះវៀនធំ, អន្តគុណំ ពោះវៀនតូច, ឧទរិយំ អាហារថ្មី, ករីសំ អាហារចាស់ ។ បិត្តំ ទឹកប្រមាត់, សេម្ហំ ទឹកស្លេស្ម៍, បុព្វោ ទឹកខ្ទុះ, លោហិតំ ទឹកឈាម, សេទោ ទឹកញើស, មេទោ ទឹកខ្លាញ់ខាប់ ។ អស្សុ ទឹកភ្នែក, វសា ទឹកខ្លាញ់រាវ, ខេឡោ ទឹកមាត់, សិង្ឃាណិកា ទឹកសម្បោរ, លសិកា ទឹកខ្លាញ់ប្រគាបឆ្អឹង, មុត្តន្តិ ទឹកមូត្រ ។

ឥតិ ឥមស្មិំ កាយេ អសុភានុបស្សី វិហរតិ ភិក្ខុមានប្រក្រតីពិចារណាឃើញរឿយៗ ដោយសភាពជារបស់មិនស្អាតក្នុងកាយនេះយ៉ាងនេះ ។

អយំ វុច្ចតានន្ទ អសុភសញ្ញា ម្នាលអានន្ទ នេះឯងតថាគតពោលថា អសុភសញ្ញា ។

★ កតមា ចានន្ទ អាទីនវសញ្ញា ម្នាលអានន្ទ អាទីនវសញ្ញានោះ ដូចម្តេច ។

ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិបដិ សញ្ចិក្ខតិ, ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ, ទៅនៅក្នុងព្រៃក្តី, ទៅនៅក្បែរគល់ឈើក្តី, ទៅនៅក្នុងផ្ទះទទេក្តី, រមែងពិចារណាយ៉ាងនេះថា ។

ពហុទុក្ខោ ខោ អយំ កាយោ ពហុអាទីនវោតិ, កាយនេះឯងមានទុក្ខច្រើន មានទោសច្រើន ។

ឥតិ ឥមស្មឹ កាយោ វិវិធា អពាធា ឧប្បជ្ជន្តិ, អាពាធគឺសេចក្តីឈឺចាប់ផ្សេងៗ រមែងកើតឡើងក្នុងកាយនេះ យ៉ាងដូច្នេះ ។

សេយ្យថីទំ អាពាធនោះគឺអ្វីខ្លះ ?

ចក្ខុរោគោ គឺរោគក្នុងភ្នែក, សោតរោគោ រោគក្នុងត្រចៀក, ឃានរោគោ រោគក្នុងច្រមុះ, ជីវ្ហារោគោ រោគក្នុងអណ្តាត, កាយរោគោ រោគក្នុងកាយ, សីសៈរោគោ រោគក្នុងក្បាល, កណ្ណរោគោ រោគត្រង់ស្លឹកត្រចៀក, មុខរោគា រោគក្នុងមាត់,

ធន្តរោគា រោគត្រង់ធ្មេញ, ភារសោ រោគក្អក, សារសោ រោគហឺត, បិនាសោ រោគឫសដូងច្រមុះ, ឌុះហោ រោគគ្រុនក្តៅ, ៩វរា រោគស្ពាំងស្តម, កុច្ឆិរោគា រោគក្នុងពោះ, មុច្ឆា រោគខ្យល់ចាប់, បក្ខន្ទិកា រោគធ្លាក់ឈាម, សុលា រោគចុកសៀត, ទិសូចិកា រោគចុះផ្ទៃ, កុដ្ឋ រោគឃ្លង់, គណ្ឌា រោគបូស, កិលាសោ រោគស្រែង, សោសោ រោគរីងរៃ, អបមារោ រោគឆ្កួតជ្រូក, ទទ្ទុ រោគដំនួចពិស, កណ្ឌូ រោគរមាស់, កច្ឆុ រោគកម, រខសា រោគបូសរលកកែវ, ទិតច្ឆិកា រោគឃ្លង់ដែក, លោហិតំ រោគឈាម, បិត្តំ រោគប្រមាត់ពុះ, មធុមេហោ រោគទឹកនោមផ្អែម, អំសា រោគឫសដូងដុះ, បិឡកា រោគពក, ភគណ្ឌលា រោគឫសដូងបាត, បិដ្ឋសមុដ្ឋានាអាពាធា អាពាធកើតអំពីប្រមាត់ឱ្យទោស, សេម្ហសមុដ្ឋានាអាពាធា អាពាធកើតអំពីស្លេស្មឹឱ្យទោស, វាតសមុដ្ឋានាអាពាធា អាពាធកើតអំពីខ្យល់ឱ្យទោស, សន្និបាតិកាអាពាធា អាពាធកើតអំពីប្រមាត់ ស្លេស្មី និងខ្យល់ទាំង ៣ ប្រជុំគ្នាឱ្យទោស, ឧតុបរិណាមជាអាពាធា អាពាធកើតអំពីរដូវប្រែប្រួល, វិសមបរិហារជាអាពាធា អាពាធកើតអំពីផ្លាស់ប្តូរឥរិយាបថមិនស្មើ, ឱបក្កមិកាអាពាធា អាពាធកើតអំពី

សេចក្តីព្យាយាមរបស់អ្នកដទៃ, កម្មវិបាកជា អាពាធា អាពាធកើត អំពីវិបាករបស់កម្ម, សីតំ អាពាធកើតអំពីត្រជាក់, ឧណ្ហំ អាពាធ កើតអំពីក្តៅ, ជិឃច្ឆា អាពាធកើតអំពីសេចក្តីឃ្លាន, បិបាសា អាពាធ កើតអំពីសេចក្តីស្រេក, ឧច្ចារោ អាពាធកើតអំពីឧច្ចារៈ, បស្សាវោតិ អាពាធកើតអំពីបស្សាវៈ ។

ឥតិ ឥមស្មឹ កាយេ អាទីនវានុបស្សី វិហរតិ, ភិក្ខុមានប្រក្រតី ពិចារណាឃើញរឿយៗ ដោយសភាពជាទោស ក្នុងកាយនេះ យ៉ាង នេះ ។

អយំ វុច្ចតានន្ទ អាទីនវសញ្ញា ម្នាលអានន្ទ នេះឯងតថាគតពោល ថាអាទីនវសញ្ញា ។

★ កតមា ចានន្ទ បហានសញ្ញា ម្នាលអានន្ទ បហានសញ្ញា នោះ ដូចម្តេច ។

ឥធានន្ទ ភិក្ខុ ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ, បជហតិ វិនោទេតិ ព្យន្តី ករោតិ អនភាវំ គមេតិ, ម្នាលអានន្ទ, ភិក្ខុក្នុង សាសនានេះ, រមែងមិនទទួល, គឺថាលះបង់, បន្ទោបង់, ធ្វើឱ្យវិនាស,

ធ្វើមិនឱ្យកើតតទៅ, នូវសេក្តីត្រិះរិះក្នុងកាមារម្មណ៍ ដែលកើតឡើងហើយ ។

ឧប្បន្នំ ព្យាបាទវិតក្កំ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ, រមែងមិនទទួល, គឺថាលះបង់, បន្ទោបង់, ធ្វើឱ្យវិនាស, ធ្វើមិនឱ្យកើតតទៅ, នូវសេចក្តីត្រិះរិះក្នុងការព្យាបាទសត្វឱ្យដល់នូវសេចក្តីវិនាស ដែលកើតឡើងហើយ ។

ឧប្បន្នំ វិហឹសា វិតក្កំ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ, រមែងមិនទទួល, គឺថាលះបង់, បន្ទោបង់, ធ្វើឱ្យវិនាស, ធ្វើមិនឱ្យកើតតទៅ, នូវសេចក្តីត្រិះរិះក្នុងការបៀតបៀនសត្វ ដែលកើតឡើងហើយ ។

ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ នាធិវា សេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ, រមែងមិនទទួល, គឺថាលះបង់, បន្ទោបង់, ធ្វើឱ្យវិនាស, ធ្វើមិនឱ្យកើតតទៅ, នូវធម៌ដែលជាបាបអកុសលទាំងឡាយ ដែលកើតឡើងហើយរឿយៗ ។

អយំ ទុច្ចតានន្ទ បហានសញ្ញា ម្នាលអានន្ទ នេះឯងតថាគតពោលថា បហានសញ្ញា ។

★កតមា ចានន្ទ វិរាគសញ្ញា ម្នាលអានន្ទ វិរាគសញ្ញានោះដូចម្តេច ។ ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ, ទៅនៅក្នុងព្រៃក្តី, ទៅនៅក្បែរគល់ឈើក្តី, ទៅនៅក្នុងផ្ទះទទេក្តី, រមែងពិចារណាយ៉ាងនេះថា ។

| | |
|---|---|
| ឯតំ សន្តំ | ធម្មជាតិនុ៎ះល្អិត, |
| ឯតំ បណីតំ | ធម្មជាតិនុ៎ះថ្លៃថ្លា, |
| យទិទំ | ធម្មជាតិនុ៎ះគឺអ្វី, |
| សព្វសង្ខារ សមថោ | គឺធម៌ជាគ្រឿងរំងាប់សង្ខារទាំងពួង, |
| សព្វូបធិប្បដិនិស្សគ្គោ | ជាគ្រឿងលះកិលេសទាំងពួង, |
| តណ្ហក្ខយោ | ជាគ្រឿងអស់ទៅនៃតណ្ហា, |
| វិរាគោ | ជាគ្រឿងប្រាសចាកតម្រេក, |
| និព្វានន្តិ | គឺព្រះនិព្វាន ។ |

អយំទុច្ចតានន្ទ វិរាគសញ្ញា ម្នាលអានន្ទ នេះឯងតថាគតពោលថា វិរាគសញ្ញា ។

★កតមា ចានន្ទ និរោធសញ្ញា ម្នាលអានន្ទ និរោធសញ្ញានោះ ដូចម្តេច ។

ឥធានន្ទ ភិក្ខុអរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ, ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ, ទៅនៅក្នុងព្រៃក្តី, ទៅនៅក្បែរគល់ឈើក្តី, ទៅនៅក្នុងផ្ទះទទេក្តី, រមែងពិចារណាយ៉ាងនេះថា ។

ឯតំ សន្តំ ធម្មជាតិនុះល្អិត,

ឯតំ បណីតំ ធម្មជាតិនុះថ្លៃថ្លា,

យទិទំ ធម្មជាតិនុះគឺអ្វី,

សព្វសង្ខារ សមថោ គឺធមិជាគ្រឿងរំងាប់សង្ខារទាំងពួង,

សព្វូបធិប្បដិនិស្សគ្គោ ជាគ្រឿងលះកិលេសទាំងពួង,

តណ្ហក្ខយោ ជាគ្រឿងអស់ទៅនៃតណ្ហា,

និរោធោ ជាគ្រឿងរលត់ស្និទ្ធ,

និព្វានន្តិ គឺព្រះនិព្វាន ។

អយំខុច្ចតានន្ទ និរោធសញ្ញា ម្នាលអានន្ទ នេះឯងតថាគតពោលថា និរោធសញ្ញា ។

★ កតមា ចានន្ទ សព្វលោកេ អនភិរតសញ្ញា ម្នាលអានន្ទ សព្វលោកេ អនភិរតសញ្ញា នោះដូចម្តេច ។

ឥធានន្ទ ភិក្ខុ យេលោកេ ឧបាយុបាទានា, ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ, ឧបាយដែលជាហេតុប្រកាន់មាំ ក្នុងលោកឯណា ។

ចេតសោ អធិដ្ឋានាភិនិវេសានុសយា, មានសេចក្តីប្រកាន់មាំដោយការតាំងចិត្ត ទុកជាអនុស័យដេកត្រាំ នៅក្នុងសន្តាន ។

តេ បជហន្តោ លោកលះឧបាយដែលជាហេតុប្រកាន់មាំនោះបង់ ។

វិរមតិ ន ឧបាទិយន្តោ លោកវៀរស្រឡះមិនប្រកាន់មាំ ។

អយំ ខុច្ចតា នន្ទ សព្វលោកេ អនភិរតសញ្ញា ម្នាលអានន្ទ នេះឯង
តថាគតពោលថា សព្វលោកេ អនភិរតសញ្ញា ។

★កតមា ចានន្ទ សព្វសង្ខារេសុ អនិច្ចសញ្ញា, ម្នាលអានន្ទ សព្វសង្ខារេសុ អនិច្ចសញ្ញា នោះដូចម្តេច ។

ឥធានន្ទ ភិក្ខុ សព្វសង្ខារេ ហិ អដ្ដីយតិ ហរា យតិ ជិគុច្ឆតិ

ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ, រមែងនឿយណាយធុញទ្រាន់ស្អប់ខ្ពើម

សង្ខារទាំងពួង ។

អយំ វុច្ចតានន្ទ សព្វសង្ខារេសុ អនិច្ចសញ្ញា, ម្នាលអានន្ទ នេះឯង

តថាគតពោលថាសព្វសង្ខារេសុ អនិច្ចសញ្ញា ។

★កតមា ចានន្ទ អានាបានស្សតិ ម្នាលអានន្ទ អានាបានស្សតិ នោះ

ដូចម្ដេច។

ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារ គតោ

វា, និសីទតិ បល្លង្កំ អាភុជិត្វា, ឧជុំ កាយំ បណិធាយ បរិមុខំ

សតឹ ឧបដ្ឋបេត្វា, សោ សតោ វ អស្សសតិ សតោ បស្សសតិ,

ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ, ទៅនៅក្នុងព្រៃក្ដី, ទៅនៅក្បែរគល់

ឈើក្ដី, ទៅនៅក្នុងផ្ទះទទេក្ដី, អង្គុយពត់ភ្នែនតម្រង់កាយ ហើយដំកល់

សតិទុកចំពោះមុខ ភិក្ខុនោះរមែងជាអ្នកមានសតិ ដកដង្ហើមចេញ,

រមែងជាអ្នកមានសតិ ដកដង្ហើមចូល,

ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ. កាលដកដង្ហើម

ចេញវែង ក៏ដឹងច្បាស់ថា យើងដកដង្ហើមចេញវែង,

ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ. កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា យើងដកដង្ហើមចូលវែង,

រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាតិ. កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា យើងដកដង្ហើមចេញខ្លី,

រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតិ. កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា យើងដកដង្ហើមចូលខ្លី,

សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នកដឹងច្បាស់ នូវគំនរខ្យល់ទាំងពួង ដកដង្ហើមចេញ,

សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ, ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នកដឹងច្បាស់ នូវគំនរខ្យល់ទាំងពួង ដកដង្ហើមចូល,

បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នករំងាប់ នូវកាយសង្ខារ គឺខ្យល់ អស្សាសៈ បស្សាសៈ ដកដង្ហើមចេញ,

បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នករំងាប់ នូវកាយសង្ខារ ដកដង្ហើមចូល,

បីតិប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នកដឹងច្បាស់នូវបីតិ គឺសេចក្តីឆ្អែតកាយ ឆ្អែតចិត្ត ដកដង្ហើមចេញ,

បីតិប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នកដឹងច្បាស់ នូវបីតិ ដកដង្ហើមចូល,

សុខប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នកដឹងច្បាស់ នូវសុខ គឺសេចក្តីសុខកាយ សុខចិត្ត ដកដង្ហើមចេញ,

សុខប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នកដឹងច្បាស់ នូវសុខ ដកដង្ហើមចូល,

ចិត្តសង្ខារប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នកដឹងច្បាស់ នូវចិត្តសង្ខារ គឺវេទនា និងសញ្ញា ដកដង្ហើមចេញ,

ចិត្តសង្ខារប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នកដឹងច្បាស់ នូវចិត្តសង្ខារ ដកដង្ហើមចូល,

បស្សម្ភយំ ចិត្តសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នករំងាប់នូវចិត្តសង្ខារ ដកដង្ហើមចេញ,

បស្សម្ភយំ ចិត្តសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នករំងាប់នូវចិត្តសង្ខារ ដកដង្ហើមចូល,

ចិត្តប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នកដឹងច្បាស់នូវចិត្ត ដកដង្ហើមចេញ,

ចិត្តប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នកដឹងច្បាស់នូវចិត្ត ដកដង្ហើមចូល,

អភិប្បមោទយំចិត្តំ អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នកធ្វើចិត្តឱ្យរីករាយ ដកដង្ហើមចេញ,

អភិប្បមោទយំចិត្តំ បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងធ្វើចិត្តឱ្យរីករាយ ដកដង្ហើមចូល,

សមាទហំចិត្តំ អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹង ដំកល់ចិត្តទុកឱ្យស្មើក្នុងអារម្មណ៍ ដកដង្ហើមចេញ,

សមាទហំចិត្តំ បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹង ដំកល់ចិត្តទុកឱ្យស្មើក្នុងអារម្មណ៍ ដកដង្ហើមចូល,

វិមោចយំចិត្តំ អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹង ដំឡោះចិត្ត ឱ្យរួចចាកនីវរណធម៌ ជាដើម ដកដង្ហើមចេញ,

វិមោចយំចិត្តំ បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹង ដំឡោះចិត្ត ឱ្យរួចចាកនីវរណធម៌ ជាដើម ដកដង្ហើមចូល,

អនិច្ចានុបស្សី អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹង ជាអ្នកពិចារណាឃើញរឿយៗ នូវបញ្ចក្ខន្ធ ថាជារបស់មិនទៀង ដកដង្ហើមចេញ,

អនិច្ចានុបស្សី បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹង ជាអ្នកពិចារណាឃើញរឿយៗ នូវបញ្ចក្ខន្ធ ថាជារបស់មិនទៀង ដកដង្ហើមចូល,

ទិរាគានុបស្សី អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នកពិចារណាឃើញរឿយៗនូវធម៌ប្រាសចាករាគៈ ដកដង្ហើមចេញ,

ទិរាគានុបស្សី បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នកពិចារណាឃើញរឿយៗ នូវធម៌ប្រាសចាករាគៈ ដកដង្ហើមចូល,

និរោធានុបស្សី អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នកពិចារណាឃើញរឿយៗ នូវធម៌ជាគ្រឿងរលត់ស្និទ្ធ នៃកងទុក្ខ ដកដង្ហើមចេញ,

និរោធានុបស្សី បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នកពិចារណាឃើញរឿយៗ នូវធម៌ជាគ្រឿងរលត់ស្និទ្ធ នៃកងទុក្ខ ដកដង្ហើមចូល,

បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នកពិចារណាឃើញរឿយៗ នូវធម៌ជាគ្រឿងលះនូវកិលេស ដកដង្ហើមចេញ,

បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុរមែងសិក្សាថា យើងនឹងជាអ្នកពិចារណាឃើញរឿយៗ នូវធម៌ជាគ្រឿងលះនូវកិលេស ដកដង្ហើមចូល

អយំវុច្ចតានន្ទ អានាបានស្សតិ ម្នាលអានន្ទ នេះឯងតថាគតពោលថា អានាបានស្សតិ ។

ស ចេ ខោ ត្វំ អានន្ទ គិរិមានន្ទស្ស ភិក្ខុនោ ឧបសង្កមិត្វា ឥមា ទសសញ្ញា ភាសេយ្យាសិ. ម្នាលអានន្ទ ថាបើលោកចូលទៅរក គិរិមានន្ទភិក្ខុហើយ, គប្បីសំដែងនូវសញ្ញា ១០ ប្រការនេះ ។

ឋានំ ខោ បនេតំវិជ្ជតិ, យំ គិរិមានន្ទស្ស ភិក្ខុនោ ឥមា ទស សញ្ញា សុត្វា, សោ អាពាធោ ឋានសោ បដិប្បស្សម្ភេយ្យាតិ. ក៏ហេតុដែលនឹងឱ្យ អាពាធរបស់គិរិមានន្ទភិក្ខុ ស្ងប់រំងាប់ទៅបាននោះ, ព្រោះបានស្តាប់នូវសញ្ញា ១០ ប្រកានេះ ។

អថ ខោ អាយស្មាអានន្ទោ ភគវតោ សន្តិកេ ឥមា ទស សញ្ញា ឧគ្គហេត្វា, យេនាយស្មា គិរិមានន្ទោ តេនុបសង្កមិ លំដាប់នោះឯង, ព្រះអានន្ទដ៏មានអាយុ រៀនយកនូវសញ្ញា ១០ ប្រការនេះ ក្នុងសំណាក់

ព្រះដ៏មានព្រះភាគហើយ, ព្រះគិរិមានន្ទដ៏មានអាយុនៅក្នុងទីណា ក៏ចូលទៅក្នុងទីនោះ,

ឧបសង្កមិត្វា អាយស្មតោ គិរិមានន្ទស្ស ឥមា ទស សញ្ញា អភាសិ លុះចូលទៅរកហើយ, ក៏បានសំដែងនូវសញ្ញា ១០ ប្រការនេះ ដល់ព្រះគិរិមានន្ទដ៏មានអាយុ ។

អថ ខោ អយស្មតោ គិរិមានន្ទស្ស ឥមា ទស សញ្ញា សុត្វា, ឋានសោ អាពាធោ ឋានសោ បដិប្បស្សម្ភិ លំដាប់នោះឯង, អាពាធរបស់គិរិមានន្ទដ៏មានអាយុ រម្ងាប់ទៅហើយ, ព្រោះបានស្ដាប់នូវសញ្ញា ១០ ប្រការនេះឯណា,

វុដ្ឋហិ ចាយស្មា គិរិមានន្ទោ តម្ហា អាពាធា. ព្រះគិរិមានន្ទដ៏មានអាយុ ក៏បានចេញហើយចាកអាពាធនោះ,

តថា បហីនោ ច បនាយស្មតោ គិរិមានន្ទស្ស សោ អពាធោ អហោសីតិ ក៏អាពាធរបស់ព្រះគិរិមានន្ទដ៏មានអាយុនោះ សាបសូន្យហើយ, ដោយការបានស្ដាប់នូវសញ្ញា ១០ ប្រការ ដែលព្រះអានន្ទសំដែងហើយ ដោយប្រការដូច្នោះ ។

ដើម្បីប្រកបដោយធមិ ៦ ចប់

# សេចក្តីបញ្ចប់

សេចក្តីឃើញជាក់ច្បាស់នូវធម៌ស្ងប់ រមែងកើតបាននូវផលធម៌ ៦ ។ ផលធម៌ ៦ នោះ គឺ :

១-មិនខឹង មិនអរ នឹងការងារ

២- មិនខឹង មិនអរ នឹងពួកគណៈ

៣- មិនខឹង មិនអរ នឹងពាក្យបញ្ចប់ប៉ប៉ោច

៤- មិនខឹង មិនអរ នឹងស៊ី ( បរិភោគ)

៥- មិនខឹង មិនអរ នឹងដេក ( ដើរ, ឈរ, អង្គុយ)

៦- ជាអ្នកមានសីលជាគ្រឿងសង្រួម

មានប្រការយ៉ាងនេះ គឺសេចក្តីចេះចាំផលធម៌ ៦ ជាមុន ទើបសជាតិបញ្ញា ប្រើប្រាស់ឯកទេសធ្វើឱ្យជាក់ច្បាស់នូវធម៌ស្ងប់ជាខាងក្រោយ ។

សេចក្តីដែលបានចុះហើយក្នុងសៀវភៅនេះ នៅមានការខ្វះចន្លោះជាច្រើនកន្លែង អ្នកត្រូវការដោយសេចក្តីប្រតិបត្តិនី មុខជាត្រូវការនូវបញ្ញាដ៏លើសរបស់ខ្លួនខានពុំបាន។ មានពាក្យពោលថា " **សៀវភៅកុំជឿ ប៉ុន្តែ កុំចោល** " ។

សូមសប្បុរសទាំងឡាយមេត្តាអនុគ្រោះផងចុះ ។ ចប់

អ្នកវាយកំព្យូទ័រៈ លោក **ពេន ចិញឌី**

អ្នកចេញថវិកាចងក្រងសៀវភៅៈ លោកស្រី **ជាច ធីឡា និងស្វាមី**

Sangha-Dana given by Upasika Cheav Villa, February 2020. For participate the transcription-work dedicated for the Sangha of the 8, directions may one feel given to join the work online on http://accesstoinsight.eu/km:lib:authors:ជា_ហាំង:សច្ចិកិរិយាកិច្ច or sangham.net.

This is a gift of Dhamma, heritage of the Sangha and given to use for share and what ever good purpose but not for commercial purpose or and kind of trade or exchange.

Anumodana!